**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**
**លេខ: ...០២៦/២៣.........អអរ**

## សេចក្តីប្រកាសព័ត៌មាន

## លទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី «ភាពជោគជ័យរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តបាត់ដំបង»

ព្រឹកថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៣ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តបាត់ដំបង»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម សុខ លូ អភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង**
- **មន្ទីរជំនាញជុំវិញខេត្តបាត់ដំបង**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងពន្យល់ និងផ្សព្វផ្សាយដល់សាធារណជនឱ្យបានជ្រាបច្បាស់អំពី យន្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងភាពជោគជ័យដែលថ្នាក់មូលដ្ឋានខិតខំប្រឹងប្រែងអនុវត្ត ព្រមទាំងសម្រេចបានសមិទ្ធផលវិជ្ជមាន ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ប្រកបដោយថាមពលរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

### I. សេចក្តីផ្តើម

ខេត្តបាត់ដំបងបែងចែកចេញជា ក្រុង០១, ស្រុកចំនួន១៣, ១០៣ឃុំ-សង្កាត់ និង៨៣៩ភូមិ។ ប្រជាពលរដ្ឋសរុប១.៣៦៧.៤០២នាក់ ក្នុងនោះ ប្រកបរបរកសិកម្មចំនួន ៦៨,៥%, សេវាកម្ម ៣១% និងផ្នែកសិប្បកម្ម០,៥% ដោយសេដ្ឋកិច្ចខេត្តបាត់ដំបង មានចំនួនស្មើនឹង ៨,៨% នៃសេដ្ឋកិច្ចជាតិ ហើយប្រាក់ចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់ៗមានចំនួន ១.៧៦០ដុល្លាអាមេរិក បើធៀបនឹងឆ្នាំ២០១៨ មានការកើនឡើងចំនួន ២២៦ដុល្លាក្នុងម្នាក់។

## II. សមិទ្ធផលសំខាន់ៗ

រដ្ឋបាលខេត្ត សម្រេចបាននូវសមិទ្ធផលសំខាន់ៗ រួមមាន៖

- **ការងារគាំពារសង្គម៖** ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល រដ្ឋបាលខេត្តបានអនុវត្តនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនដល់គ្រួសារក្រីក្រ និងងាយរងគ្រោះមានជាង ៩ម៉ឺនគ្រួសារ ចំណាយថវិកាអស់ប្រមាណ ៥០០ពាន់លានរៀល, ស្ត្រីមានផ្ទៃពោះ ជិត ២ម៉ឺននាក់ និងកុមារមានអាយុក្រោម ២ឆ្នាំ ជិត ៦ពាន់នាក់។ រដ្ឋបាលខេត្ត បាននិងកំពុងជំរុញបន្តការអនុវត្តនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់នេះ ជូនប្រជាពលរដ្ឋជាបន្តបន្ទាប់ ជាពិសេសចំពោះគ្រួសារដែលងាយរងហានិភ័យ។
- **វិស័យកសិកម្ម៖** កត្តាភូមិសាស្ត្រអំណោយផល ផ្ទៃដីមានជីជាតិល្អសម្រាប់ផលកសិកម្ម ខេត្តបាត់ដំបង បានជាប់ឈ្មោះជាខេត្តជង្រុកស្រូវនៃព្រះរាជាណាចក្រកម្ពុជា ដោយប្រជាពលរដ្ឋប្រកបរបរកសិកម្មប្រមាណជាង៦៨% ដែលជាការរួមចំណែកយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។ ខេត្តមានផ្ទៃដីដាំដុះស្រូវសរុបចំនួន ៤១៤.៧៦១ ហិកតា ទទួលបានបរិមាណចន្លោះពី ១.១លានតោន ទៅ ១,៤លានតោន ក្នុងមួយឆ្នាំៗ ដែលមានប្រភពទឹកផ្គត់ផ្គង់ចំនួន៤ប្រព័ន្ធធំៗរួមមាន៖ ប្រព័ន្ធធារាសាស្ត្រស្ទឹងសង្កែ ប្រព័ន្ធធារាសាស្ត្រស្ទឹងមោងឬស្សី ប្រព័ន្ធធារាសាស្ត្រស្ទឹងមង្គលបុរី និងប្រព័ន្ធធារាសាស្ត្រអាងកំពីងពួយ។ រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់ចំពោះបញ្ហាតម្លៃស្រូវ តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ ក្នុងការផ្តល់នូវប្រាក់កម្ចី ក្នុងអត្រាការប្រាក់ទាប ដល់ប្រជាកសិករ និងម្ចាស់អាជីវកម្មរោងម៉ាស៊ីនកិនស្រូវ ដើម្បីចូលរួមចំណែករក្សានូវស្ថិរភាពតម្លៃស្រូវនេះ។
- **វិស័យទេសចរណ៍៖** ទេសចរណ៍ គឺជាវិស័យមួយដែលចូលរួមចំណែកក្នុងការលើកកម្ពស់សេដ្ឋកិច្ចខេត្ត ក៏ដូចជាជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ តាមរយៈការបង្កើតការងារជូនប្រជាពលរដ្ឋដោយផ្ទាល់ និងដោយប្រយោល។ ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ ភ្ញៀវទេសចរជាតិ និងអន្តរជាតិមកទស្សនាខេត្តបាត់ដំបងសរុបចំនួន ២.៥៧១.៦៨៧នាក់ ក្នុងនោះភ្ញៀវទេសចរជាតិចំនួន ២.៣១៤.១២៦ នាក់ និងភ្ញៀវទេសចរអន្តរជាតិចំនួន ២៥៧.៥៦១ នាក់។
- **វិស័យសាធារណការ៖** ខេត្តបានផ្តោតសំខាន់លើការងារហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ដោយបានបន្តកសាង ជួសជុល ថែទាំ ផ្លូវជាតិ ផ្លូវខេត្ត និងបន្តកសាងផ្លូវខេត្ត ផ្លូវជនបទ ឱ្យមានគុណភាពខ្ពស់ ក្នុងគោលបំណងតភ្ជាប់បណ្តាញផ្លូវពីទីរួមខេត្ត ទៅស្រុក និងពីស្រុកមកទីរួមខេត្ត ជាពិសេសគម្រោងសាងសង់ផ្លូវជាតិលេខ១០ ដែលចេញពីស្រុកសំឡូត ខេត្តបាត់ដំបង ឆ្លងកាត់ខេត្តពោធិ៍សាត់ ឆ្ពោះទៅកាន់ខេត្តកោះកុង បាននឹងកំពុងដំណើរការសាងសង់សម្រេចបានប្រមាណ ៦៩,២៨% នឹងគ្រោងបញ្ចប់នៅចុងឆ្នាំ២០២៤ខាងមុខនេះ។ គួរបញ្ជាក់ផងដែរថា

បច្ចុប្បន្ននេះ ទូទាំងខេត្តទាំងមូល សម្រេចបាននូវការកសាងផ្លូវកៅស៊ូឆ្លងកាត់ឃុំ-សង្កាត់សរុប បានចំនួន ៩៧ឃុំ-សង្កាត់។

- **ការងារទឹកស្អាត និងអគ្គិសនី៖** អង្គភាពរដ្ឋាករទឹកស្អាតបាត់ដំបង បានអនុវត្តការផ្គត់ផ្គង់ទឹកស្អាតជូនដល់ប្រជាពលរដ្ឋក្នុងក្រុង-ស្រុកចំនួន៣ ដែលមាន៨៥ភូមិ ស្មើនឹងប្រមាណជាង ៦៨% និងមានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន ២៤ កន្លែង ដែលកំពុងផ្តល់សេវាទឹកស្អាតជូនប្រជាពលរដ្ឋចំនួន ៤៥១ភូមិ។ ចំណែកការផ្គត់ផ្គង់អគ្គិសនីវិញ ប្រជាពលរដ្ឋចំនួន ៩០,៣២% បានទទួលអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ ជាមួយគ្នានេះ ខេត្តកំពុងធ្វើការពង្រីកការតភ្ជាប់បណ្តាញអគ្គិសនីបន្ថែមទៀតដល់មូលដ្ឋានភូមិ-ឃុំ ជាពិសេសនៅតាមតំបន់ជនបទ។

## III. សម្គាល់

ក្រុងបាត់ដំបងបានជាប់ក្នុងបញ្ជី **"បណ្តាញទីក្រុងឆ្លាតអាស៊ាន"**។ រដ្ឋបាលខេត្ត បានខិតខំបន្តជំរុញលើកកម្ពស់សោភ័ណភាព សណ្តាប់ធ្នាប់ទីក្រុង និងជំរុញអនុវត្តការងារទីក្រុងឆ្លាត ដោយបានដាក់ចេញនូវគម្រោងអភិវឌ្ឍន៍សំខាន់ៗចំនួន ២គឺ៖ ការគ្រប់គ្រងលំហសាធារណៈនិងចំណីផ្លូវ និងការគ្រប់គ្រងសំណល់រឹង និងរាវ។ ជាមួយគ្នានេះ រដ្ឋបាលខេត្ត សម្រេចបាននូវការសាងសង់ទីលានកប់សំរាមមួយកន្លែង ដែលមានផ្ទៃដីសរុប ២០,៨ហិកតា ដោយក្នុងនោះ មានអគារស្នាក់នៅ, ការិយាល័យ, ជញ្ជីងថ្លឹង, រោងញែកសំរាម, រោងជាង, រោងសំណល់គ្រោះថ្នាក់, កន្លែងលាងរថយន្ត, រណ្តៅសំណល់ គ្រោះថ្នាក់, រណ្តៅកប់សំរាមទី១, អាងប្រព្រឹត្តកម្មទឹកកខ្វក់ចេញពីសំរាម និងបំរុងសម្រាប់រណ្តៅកប់សំរាម៕ Den

ថ្ងៃអង្គារ ៣កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៣